# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មាធិការព្រំដែនខេត្ត ក្រចេះ ជាប់ព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៧៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខនស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៩១៤ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេសកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៩១៥ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង

-បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញសេចក្តីសម្រេចលេខ១៧ សសរ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា-ថៃ

-បានឃើញសេចក្តីសម្រេចលេខ១៨ សសរ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា-ឡាវ

-បានឃើញសេចក្តីសម្រេចលេខ១៩ សសរ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម

-បានឃើញសេចក្តីសម្រេចលេខ១៤ សសរចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម

-យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១ :**

ត្រូវបានបង្កើតអនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុង ជាប់ព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង ចំណុះលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ២ :**

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- អភិបាលខេត្ត ក្រុង ជាប់ព្រំដែន | ប្រធាន |
| ២-អភិបាលរងខេត្ត ក្រុង ជាប់ព្រំដែន មួយរូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-មេបញ្ជាការយោធភូមិភាគ នៃបណ្តាខេត្ត ក្រុង ជាប់ព្រំដែន | អនុប្រធាន |
| ៤-នាយខុទ្ទកាល័យខេត្ត ក្រុង ជាប់ព្រំដែន | សមាជិក |
| ៥-ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្ត ក្រុង ជាប់ព្រំដែន | សមាជិក |
| ៦-ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង ជាប់ព្រំដែន | សមាជិក |
| ៧-ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត ក្រុង ជាប់ព្រំដែន | សមាជិក |
| ៨-ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក្រុង ជាប់ព្រំដែន | សមាជិក |

៩- មេបញ្ជាការប្រតិបត្តិការស៊ើបការខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១០-មេបញ្ជាការមូលដ្ឋានទ័ពជើងទឹកខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១១-មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១២-ស្នងការនគរបាលខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១៣-អភិបាលស្រុក ខណ្ឌ នៃខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១៤-ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារព្រំដែនអន្តរជាតិ សមាជិក

១៥-ប្រធានសាខាគយ និងរដ្ឋាករ នៅតាមខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១៦-នាយនគរបាលអន្តោប្រវេសន៍ នៅតាមច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារព្រំដែនអន្តរជាតិ សមាជិក

១៧-ប្រធានសាខាកាំកុងត្រូល នៅតាមខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១៨-មេបញ្ជាការកងវរៈការពារព្រំដែន នៃកងយោធពលខេមរភូមិន្ទ ដែលឈរជើងតាមខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១៩-នាយនគរបាលជាតិវរៈការពារព្រំដែនគោក នៃស្នងការនគរបាលខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

សមាសភាពជាក់ស្តែង នៃអនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ ត្រូវកំណត់ដោយដីកាសាលាខេត្ត ក្រុង សាមីនីមួយៗ ។

**ប្រការ៣ :**

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ ជាជំនួយការឱ្យលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

១-សម្របសម្រួលការងារដល់ក្រុមប្រតិបត្តិការ និងក្រុមបច្ចេកទេសវាស់វែង ដែលចុះបំពេញបេសកកម្មក្នុងទឹកដីខេត្ត ក្រុង របស់ខ្លួន ។

២-សម្របសម្រួលការងារសាងសង់បង្គោលព្រំដែននៅលើដីជាក់ស្តែង ជាមួយខេត្តជាដៃគូ នៃភាគីម្ខាងទៀត ដោយមានការចូលរួមដឹកនាំបច្ចេកទេសពីអ្នកជំនាញបច្ចេកទេស នៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

៣-សិក្សា និងលើកគម្រោង ស្តីពីការអភិវឌ្ឍតាមបណ្តោយព្រំដែន ជូនលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

៤-ចូលរួមសហការជាមួយភាគីម្ខាងទៀត ក្នុងការថែរក្សាបង្គោលព្រំដែន ដែលបានបោះរួច ហើយលើដីជាក់ស្តែង និងឃ្លាំមើលសភាពការណ៍មិនប្រក្រតីដែលកើតមានឡើង ដូចជា ការផ្លាស់ប្តូទីតាំង បង្គោល ឬបង្គោលព្រំដែន ដែលមានការបែកបាក់ដោយប្រការណាមួយ និងធ្វើរបាយការណ៍មកលេខាធិការ-ដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីមានវិធានការចាំបាច់ ។

៥-ធ្វើរបាយការណ៍ជូនលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន អំពីគម្រោងអភិវឌ្ឍន៍នៃភាគីម្ខាងទៀត ដែលមានទីតាំងជាប់នឹងខ្សែព្រំដែន ដើម្បីឱ្យគណៈកម្មាធិការ ចម្រុះកិច្ចការព្រំដែន មានវិធានការជាមួយនឹងភាគីម្ខាងទៀត ។

៦-រៀបចំទុកដាក់ និងថែរក្សាឯកសារពាក់ព័ន្ធនឹងព្រំដែន ដែលលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនប្រគល់ជូន ។

៧-ប្រមូលព័ត៌មាន ស្តីពីសភាពការណ៍ពាក់ព័ន្ធទៅនឹងការគ្រប់គ្រង ការឆ្លងកាត់ព្រំដែន ដែល កើតឡើងនៅតាមបណ្តោយព្រំដែនក្នុងទឹកដីនៃខេត្ត ក្រុង របស់ខ្លួន ។

៨-អនុវត្តឱ្យបានសម្រេចតាមផែនការ ទិសដៅ និងភារកិច្ច ដែលលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនប្រគល់ជូន ។

៩-ធ្វើរបាយការណ៍តាមដំណាក់កាលនីមួយៗ អំពីសភាពការណ៍ព្រំដែន និងការដោះស្រាយបញ្ហា នានានៅតាមព្រំដែនក្នុងទឹកដីនៃខេត្ត ក្រុងរបស់ខ្លួន ការបោះបង្គោលព្រំដែនលើដីជាក់ស្តែង ការឆ្លងកាត់ ព្រំដែន ការអភិវឌ្ឍតាមតំបន់ព្រំដែន ជូនប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួល បន្ទុកកិច្ចការព្រំដែន ។

**ប្រការ៤ :**

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ មានលេខាធិការដ្ឋាន ជាសេនាធិការ ដែលមានទីតាំង នៅក្នុងសាលាខេត្ត ក្រុង នៃបណ្តាខេត្ត ក្រុងជាប់ព្រំដែន ។

លេខាធិការដ្ឋាននេះ មាននាយខុទ្ទកាល័យខេត្ត ក្រុង ជាប្រធាន និងមានមន្ត្រីជំនាញពី ៣នាក់ ទៅ ៥នាក់ ជាជំនួយការ ។

សមាសភាពជាក់ស្តែង នៃប្រធាន និងមន្ត្រីជំនាញ របស់លេខាធិការដ្ឋាននៃអនុគណៈកម្មាធិការ ព្រំដែនខេត្ត ក្រុងនេះ ត្រូវកំណត់ដោយដីកាសាលាខេត្ត ក្រុងសាមីនីមួយៗ ។

**ប្រការ៥ :**

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុងសាមី។

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ ត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៦ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៧ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងអភិបាលខេត្ត ក្រុង ដែលពាក់ព័ន្ធ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ១៣ ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល:**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ